ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**

Nation Religion King

អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
មកដល់ថ្ងៃ.....ទី ០៥ ខែ ០១ ឆ្នាំ ០៧
ចុះបញ្ជីលេខ ០៣៤

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

**Ministry of Industry, Mines and Energy**

Nº ០០៤ ឧរថ.ឧគស-សណន.

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ២០០៦

ក្រសួងសុខាភិបាល
ចូលមក ការិយាល័យ
ថ្ងៃទី 04 ខែ 01 ឆ្នាំ 2007 ម៉ោង.......នាទី
ចុះបញ្ជីលេខ 042

មជ្ឈ.លើកកំពស់សុខភាព
ចូលថ្ងៃទី 12 ខែ 01
2007 ម៉ោង 11 នាទី 20
ចុះបញ្ជីលេខ 012

## សេចក្ដីណែនាំ

## ស្ដីពី

## ការហាមជក់បារីនៅកន្លែងធ្វើការ សាលប្រជុំ

យោងតាមខ្លឹមសារនៃលិខិតរបស់ទីស្ដីការគណៈរដ្ឋមន្ត្រីលេខ ១២៧០ សជណ ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ១៩៩៤ ស្ដីពីគោលការណ៍ហាមជក់បារីនៅកន្លែងធ្វើការ សាលប្រជុំ និងយោងតាមស្មារតីអង្គសិក្ខាសាលាថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ២០០៦ ដែលបានបង្ហាញឱ្យឃើញអំពីផលវិបាកនៃការជក់ និងការស្រូបផ្សែងបារីពីអ្នកជក់ បានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សុខភាព បរិស្ថាន ធ្វើឱ្យខាតបង់ថវិកាគ្រួសារ និងសេដ្ឋកិច្ចជាតិ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សូមធ្វើការណែនាំដូចតទៅ :

១- ហាមជក់បារីនៅក្នុងបន្ទប់ធ្វើការ សាលប្រជុំ បន្ទប់ទឹក និងតាមផ្លូវដើរចេញចូលកន្លែងធ្វើការ ។

២- ស្នើចូលរួមធ្វើការអប់រំស្ដីពីផលប៉ះពាល់សុខភាពដោយសារការប្រើប្រាស់ថ្នាំជក់ ដើម្បីទប់ស្កាត់ ឬ កាត់បន្ថយការជក់ រហូតឈានដល់ការលះបង់ទម្លាប់ជក់បារីទាំងស្រុង ។

៣- ក្នុងករណីមានការល្មើសពីសេចក្ដីណែនាំដែលបានរៀបរាប់ខាងលើ ត្រូវទទួលការណែនាំ ។

គ្រប់នាយកដ្ឋាន និងមន្ទីរខេត្ត-ក្រុងក្រោមឱវាទក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានភារៈកិច្ចអនុវត្តសេចក្ដីណែនាំនេះឱ្យបានលទ្ធផលល្អប្រសើរ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន:
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាក់ព័ន្ធ
- អង្គការគ្រប់គ្រងភិបាល "ដើម្បីជ្រាប"
- គ្រប់នាយកដ្ឋាន
- មន្ទីរឧ.រ.ថ ខេត្ត-ក្រុង "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ